ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី១៩ លេខ២៩ ត្រីមាសទី០២ ឆ្នាំ២០១៩

# រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច សារាចរ ប្រកាស

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

១៩-០៣-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៣១៩/៤៣៩ ស្ដីពី ការផ្ដល់នីតិសម្បទាឡើងវិញឱ្យឈ្មោះ **ចំន្ទ សិលា** ភេទ ប្រុស កើតថ្ងៃទី ២០ ខែតុលា ឆ្នាំ១៩៦០ ដែលត្រូវបានហាមឃាត់មិនឱ្យធ្វើសកម្មភាពនយោបាយសម្រាប់រយៈពេល ៥ (ប្រាំ)ឆ្នាំ តាមអំណាចសាលដីកាលេខៈ ៣៤០(ឆ) ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់តុលាការកំពូល ៣២២១

២៧-០៣-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៣១៩/៤៤០ ស្ដីពី ការតែងតាំងឯកឧត្តម **គង់ វ៉ាញ** ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជំនួសឯកឧត្តម **គីម សុន** ដែលបានទទួលភារកិច្ចថ្មី ៣២២២

២៧-០៣-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៣១៩/៤៤១ ស្ដីពី ការតែងតាំង និងផ្ដល់ឋានៈ ដល់ឯកឧត្តមចំនួន ០៧រូប នៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ៣២២៣

២៧-០៣-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៣១៩/៤៤២ ស្ដីពី ការនិយ័តកម្មឋានន្តរស័ក្តិ និងថ្នាក់តាមអតីតភាពការងារ ជាករណីពិសេស ដល់លោកស្រី **តាំង សុគន្ធមាលា** នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងពាណិជ្ជកម្ម ៣២២៥

២៧-០៣-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៣១៩/៤៤៣ ស្ដីពី ការផ្ទេរក្របខ័ណ្ឌលោក **សយ សុវណ្ណ** នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ មកឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ៣២២៦

២៧-០៣-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៣១៩/៤៤៤ ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈដល់សពលោកវរសេនីយ៍ឯក **ខ៊ាន់ នី** នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៣២២៧

២៧-០៣-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៣១៩/៤៤៥ ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ២៨រូប ៣២២៨

២៧-០៣-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៣១៩/៤៤៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់កញ្ញា **វ៉ាង វ៉ាយលីង** (WANG WEI-LING) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ ៣២៣០

២៧-០៣-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៣១៩/៤៤៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លីវ ជុនអ៊ី** (LIU, JIUN-YI) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ ៣២៣១

២៧-០៣-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៣១៩/៤៤៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លាំង ចៀហាវ** (LIANG, CHIA-HAO) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ ៣២៣២

២៧-០៣-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៣១៩/៤៤៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **សេង ហ្វានចេង** (ZENG, FANCHENG) ជនជាតិចិន សញ្ជាតិចិន ដោយប្តូរឈ្មោះជា **សេង ចេង** (ZENG CHENG) ៣២៣៣

២៧-០៣-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៣១៩/៤៥០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លូ ដាវហ្គួយ** (LU, DAOGUI) ជនជាតិចិន សញ្ជាតិចិន ៣២៣៤

២៧-០៣-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៣១៩/៤៥១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ហ៊ុង ចាន់វ៉េ** (LUNG, CHAN-WEI) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ ៣២៣៥

២៩-០៣-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៣១៩/៤៥៣ ស្តីពី ការតែងតាំងឯកឧត្តម **ប៊ួន សារៈមុនី** ជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ៣២៣៦

២៩-០៣-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៣១៩/៤៥៤ ស្តីពី ការតែងតាំង និងផ្តល់ឋានៈមេធាវីរាជរដ្ឋាភិបាល ចំនួន ០៣រូប ៣២៣៧

២៩-០៣-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៣១៩/៤៥៥ ស្តីពី ការតែងតាំងជារដ្ឋលេខាធិការ និងជាអនុរដ្ឋលេខាធិការ នៃក្រសួងចំនួន ០៤ ដល់ឯកឧត្តម និងលោកជំទាវ ចំនួន ០៤រូប ៣២៣៨

២៩-០៣-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៣១៩/៤៥៦ ស្តីពី ការតែងតាំង និងផ្តល់ឋានៈជាទីប្រឹក្សារាជរដ្ឋាភិបាល ០៧រូប ៣២៣៩

២៩-០៣-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៣១៩/៤៥៧ ស្តីពី ការផ្ទេរបញ្ចូលលោកវរសេនីយ៍ទោ **គាត ហ៊ុល** នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៣២៤០

២៩-០៣-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៣១៩/៤៥៨ ស្តីពី ការតម្លើងឋានន្តរស័ក្តិឧត្តម អគ្គានុរក្សពន្ធនាគារ ដល់មន្ត្រីពន្ធនាគារ ចំនួន ១១ រូប នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ៣២៤១

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

១០-០១-២០១៩ -អនុក្រឹត្យលេខ ១២ អនក្រ.បក ស្តីពី ការកែសម្រួលមាត្រា ១ មាត្រា ២ និងមាត្រា ៣ នៃអនុក្រឹត្យលេខ ១២៦ អនក្រ.បក ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១៦ ស្តីពី ការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការពារការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះ បោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ ២០១៦ ដល់ឆ្នាំ២០១៩ ៣២៤៣

២៣-០៥-២០១៩ -អនុក្រឹត្យលេខ ៧០ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៣២៤៦

២៤-០៥-២០១៩ -អនុក្រឹត្យលេខ ៧១ អនក្រ.បក ស្តីពី ការកែប្រែនិងការតម្លើងប្រាក់បំណាច់ចៅក្រមនិង ព្រះរាជអាជ្ញា ៣២៤៨

០៣-០៦-២០១៩ -អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ៣២៥៣

១៨-០១-២០១៩ -អនុក្រឹត្យលេខ ៤៧ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ៣២៥៥

២៧-០៣-២០១៩ -អនុក្រឹត្យលេខ ៣៦៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣២៥៦

២៧-០៣-២០១៩ -អនុក្រឹត្យលេខ ៣៧០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣២៥៨

២៧-០៣-២០១៩ -អនុក្រឹត្យលេខ ៣៧១ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣២៦០

០១-០៤-២០១៩ -អនុក្រឹត្យលេខ ៣៧២ អនក្រ.តត ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ៣២៦១

០១-០៤-២០១៩ -អនុក្រឹត្យលេខ ៣៧៣ អនក្រ.តត ស្តីពី ការតម្លើងថ្នាក់មន្ត្រីរាជការ ៣២៦៨

០១-០៤-២០១៩ -អនុក្រឹត្យលេខ ៣៧៤ អនក្រ.តត ស្តីពី ការតម្លើងថ្នាក់មន្ត្រីរាជការ ៣២៧០

០១-០៤-២០១៩ -អនុក្រឹត្យលេខ ៣៧៥ អនក្រ.តត ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ៣២៧៣

០១-០៤-២០១៩ -អនុក្រឹត្យលេខ ៣៧៦ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៣២៩១

០១-០៤-២០១៩ -អនុក្រឹត្យលេខ ៣៧៧ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ ៣២៩២

០១-០៤-២០១៩ -អនុក្រឹត្យលេខ ៣៧៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣២៩៧


## ២-សេចក្តីសម្រេច


០៩-០៤-២០១៩ -សេចក្តីសម្រេចលេខ ៥៩ សសរ ស្តីពី ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សា និងដោះស្រាយបញ្ហាបាក់ច្រាំងទន្លេបាសាក់-ទន្លេហ៊ូវ និងព្រែកជ្រៃធំ-ព្រែកបិញយី នៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ៣២៩៨

១៩-០៤-២០១៩ -សេចក្តីសម្រេចលេខ ៦០ សសរ ស្តីពី ការបង្កើតគណៈកម្មការអន្តរក្រសួង សម្រាប់រៀបចំពិធីតភ្ជាប់មុខតំណស្ពានមិត្តភាពកម្ពុជា-ថៃ (ស្ទឹងបត់-បានណងអៀន) ពិធីបើកការដ្ឋានសាងសង់អគារច្រកទ្វារព្រំដែនស្ទឹងបត់ និងពិធីប្រគល់-ទទួលក្បាល រថភ្លើង (DMU) ៣៣០១

២៣-០៤-២០១៩ -សេចក្តីសម្រេចលេខ ៦១ សសរ ស្តីពី ការបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តព្រះសីហនុ ៣៣០៤

២៣-០៤-២០១៩ -សេចក្តីសម្រេចលេខ ៦២ សសរ ស្តីពី ការបំពេញបន្ថែម និងកែសម្រួលសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តស្ទឹងត្រែង ៣៣០៦

២៥-០៤-២០១៩ -សេចក្តីសម្រេចលេខ ៦៣ សសរ ស្តីពី ការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៣៣០៨


## III-ការិយាល័យក្រសួង

## ១-ទីស្តីការក្រសួងមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


១១-០៤-២០១៩ -សេចក្តីសម្រេចលេខ ០៥០ សហវ ស្តីពី ការកែសម្រួលសមាសភាពគណៈកម្មាធិការអនុវត្តការងារទិញ សាងសង់ ជួសជុល បំពាក់សម្ភារ ឧបករណ៍ គ្រឿងសង្ហារឹម និងអចលនទ្រព្យរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ៣៣០៩

១២-០៤-២០១៩ -សារាចរណែនាំលេខ ០០២ សហវ ស្តីពី កិច្ចបញ្ជិកាគណនេយ្យលើការផ្តល់ឧបត្ថម្ភធនរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ៣៣១៣

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

១៥-១១-២០១៨ -ប្រកាសលេខ ៣៧៧ ឧស.កឧ.ប្រក១១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វាយ ស្ទេត ចីប៉ែកខូ ឯ.ក បង្កើតរោងចក្រ ផលិតបារី ៣៣១៧

១៥-១១-២០១៨ -ប្រកាសលេខ ៣៧៨ ឧស.កឧ.ប្រក១១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខេមបូឌាន សៅអ៊ីស្ត អេស៊ា ចីប៉ែខូ ឯ.ក បង្កើតរោងចក្រ ផលិតបារី ៣៣២០

## ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល

០៣-១២-២០១៨ -ប្រកាសលេខ ០១៥៤ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ លេខ ០១៥៤ រថ.អប្រក.លអ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៨ ៣៣២៣

០៣-១២-២០១៨ -ប្រកាសលេខ ០១៥៥ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ លេខ ០១៥៥ រថ.អប្រក.លអ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៨ ៣៣២៧

០៣-១២-២០១៨ -ប្រកាសលេខ ០១៦២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ លេខ ០១៦២ រថ.អប្រក.លអ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៨ ៣៣៣១

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៩/៤៣៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៧/០០៣ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៧ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឲ្យច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១១៩/០០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានផ្តល់នីតិសម្បទាឡើងវិញឲ្យឈ្មោះ ច័ន្ទ សិលា ភេទ ប្រុស កើតថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៦០ ដែលត្រូវបានហាមឃាត់មិនឲ្យធ្វើសកម្មភាពនយោបាយសម្រាប់រយៈពេល៥(ប្រាំ)ឆ្នាំ តាមអំណាចសាលដីកាលេខៈ ៣៤០(ឆ) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់តុលាការកំពូល។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១៩

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

៣៧៧.១៩០៣.៤៤៣

ស.ខ.

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៩/៤៤០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: តែងតាំងឯកឧត្តម **គង់ ម៉ាញ** ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជំនួសឯកឧត្តម **គឹម សុន** ដែលបានទទួលភារកិច្ចថ្មី ។

**មាត្រា ២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០១៩*

**ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

៣៩៧.ឈ៩០៣.៤៤៤

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៩/៤៤១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងនិងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង និងផ្តល់ឋានៈឯកឧត្តម **ម៉ូច ចរិយា** ជាប្រធាននិយ័តករទូរគមនាគមន៍កម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ**។

**មាត្រា២ :** តែងតាំង និងផ្តល់ឋានៈជាសមាជិកនិយ័តករទូរគមនាគមន៍កម្ពុជា ០៤រូប៖

១. ឯកឧត្តម **អ៊ឹម ឧត្តរា** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**
២. ឯកឧត្តម **អ្នូក ដូរ៉ានី** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**
៣. ឯកឧត្តម **សេង សុទ្ធី** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**
៤. ឯកឧត្តម **ជា ច័ន្ទតារ៉ា** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា៣ :** តែងតាំង និងផ្ដល់ឋានៈជាទីប្រឹក្សាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ០២រូបៈ

១. ឯកឧត្តម **សរ រតនា** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

២. ឯកឧត្តម **ស៊ា ណារ៉េត** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**។

**មាត្រា៤ :** ប្រធាន និងសមាជិកនៃនិយ័តករទូរគមនាគមន៍កម្ពុជា ដូចមានចែងក្នុងមាត្រា១ និងមាត្រា២ ត្រូវបានតែងតាំងសម្រាប់អាណត្តិទី២។ ប្រធាន និងសមាជិកមានអាណត្តិ៣(បី)ឆ្នាំ។

**មាត្រា៥ :** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០១៩

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាបន្ទាប់**

**ប្រមុខរដ្ឋស្ដីទី**

នស.រកត.១៩០៣.៤៤៥

**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៩/៤៤២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** និយ័តកម្មឋានន្តរស័ក្តិ និងថ្នាក់តាមអតីតភាពការងារ ជាករណីពិសេស ដល់លោកស្រី **តាំង សុគន្ធមាលា** ពីឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ ៣ មកឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងពាណិជ្ជកម្ម។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៩

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

[illegible]

(signature)

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

(signature)

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៩/៤៤៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ដែលស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: ផ្ទេរក្របខ័ណ្ឌលោក **សយ សុវណ្ណ** ពីឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ៤ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ មកឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** អត្តលេខ ៨៤៦១១ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ។

**មាត្រា ២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៩*

**ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

៣៩៧.១៧៣.៤៤៧

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៩/៤៤៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ដំឡើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ជាកិច្ចបច្ចាមរណៈដល់សពលោកវរសេនីយ៍ឯក **ម៉ាន់ នី** អត្តលេខ ៦២០០៩ នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៩

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ពរស. ១៩០៣. ៤៤៥

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៩/៤៤៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** ៖ តម្លើងឋាននន្តរស័ក្តិដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

**ក- ថ្នាក់ឧត្តមសេនីយ៍ឯក**

១- ឧត្តមសេនីយ៍ទោ **អ៊ឹម សារឿន** អត្តលេខ ៣៧៦២៤
២- ឧត្តមសេនីយ៍ទោ **ឈូ សារុំ** អត្តលេខ ៧១៨៦៦
៣- ឧត្តមសេនីយ៍ទោ **អេង គីមហៃ** អត្តលេខ ៧៣៥៨៦ ។

**ខ- ថ្នាក់ឧត្តមសេនីយ៍ទោ**

១- ឧត្តមសេនីយ៍ត្រី **ទ៊ីង មិនា** អត្តលេខ ០២១១១
២- ឧត្តមសេនីយ៍ត្រី **គង់ ម៉ាដា** អត្តលេខ ០២២៧៤
៣- ឧត្តមសេនីយ៍ត្រី **ហេង រស្មី** អត្តលេខ ០៥១១៨
៤- ឧត្តមសេនីយ៍ត្រី **ប្រាក់ វ៉ូហ្សា** អត្តលេខ ០៥២៣៩

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| | | | | |
|---|---|---|---|---|
| ៥- | ឧត្តមសេនីយ៍ត្រី | **ឃី តិរីវ៉ុត្ថ** | អត្តលេខ | ០៥៥៣៩ |
| ៦- | ឧត្តមសេនីយ៍ត្រី | **អ៊ុំ ចំរើន** | អត្តលេខ | ០៨៦៩៥ |
| ៧- | ឧត្តមសេនីយ៍ត្រី | **ឌុប ឈុត** | អត្តលេខ | ១២៤៩៣ |
| ៨- | ឧត្តមសេនីយ៍ត្រី | **លឹម ហុកលី** | អត្តលេខ | ៤១០៦៨ |
| ៩- | ឧត្តមសេនីយ៍ត្រី | **កិ គឹមសាន្ត** | អត្តលេខ | ៦០៧៨៩ |
| ១០- | ឧត្តមសេនីយ៍ត្រី | **លី សារ៉ាវិទ្ធ** | អត្តលេខ | ៦៨១៦៨ |
| ១១- | ឧត្តមសេនីយ៍ត្រី | **អ៊ុំ វាសនា** | អត្តលេខ | ៧៧១៦៨ ។ |

**គ- ថ្នាក់ឧត្តមសេនីយ៍ត្រី**

| | | | | |
|---|---|---|---|---|
| ១- | វរសេនីយ៍ឯក | **អ៊ុត សុខុម** | អត្តលេខ | ០១៤៨៧ |
| ២- | វរសេនីយ៍ឯក | **សេម សឿន** | អត្តលេខ | ០៥៤៩១ |
| ៣- | វរសេនីយ៍ឯក | **ឈឹម ស៊ុខហ៊ីរ** | អត្តលេខ | ០៥៧៧៣ |
| ៤- | វរសេនីយ៍ឯក | **សែ វង្សផាន់** | អត្តលេខ | ០៦០២៧ |
| ៥- | វរសេនីយ៍ឯក | **ហេង សៀកឡាយ** | អត្តលេខ | ២៦០០៩ |
| ៦- | វរសេនីយ៍ឯក | **ណាយ យ៉ាង** | អត្តលេខ | ៣០៧៥០ |
| ៧- | វរសេនីយ៍ឯក | **នៅ សំអុល** | អត្តលេខ | ៥៥៩២៧ |
| ៨- | វរសេនីយ៍ឯក | **សុខ ថា** | អត្តលេខ | ៥៦០៦៨ |
| ៩- | វរសេនីយ៍ឯក | **អ៊ុក ចិមល** | អត្តលេខ | ៦២៧៤៣ |
| ១០- | វរសេនីយ៍ឯក | **តុប សំភី** | អត្តលេខ | ៧១៩៣៨ ។ |

**មាត្រា ២** ៖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៩

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាស់បន្ទាប់**

**ប្រមុខរដ្ឋស្តីទី**

នសល.១៩៣.៤៤៩

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៩/៤៤៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់កញ្ញា **វ៉ាង វ៉ាយលីង** (WANG WEI-LING) ជនជាតិ ចិនតៃវ៉ាន់ សញ្ជាតិ ចិនតៃវ៉ាន់ កើតថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨៥ នៅខេត្តតៃវ៉ាន់ សាធារណរដ្ឋចិន ។

**មាត្រា ២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៩*

**ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

៣៧.១៩៣.៤៤០

ស.រ.

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៩/៤៤៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លីវ ជុនអ៊ី** (LIU, JIUN-YI) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ កើតថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ១៩៧៩ នៅទីក្រុង New Taipei សាធារណរដ្ឋចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៩

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

៣៧៥.១៩៣៣.៤៥១

(ហត្ថលេខា)

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

(ហត្ថលេខា និងត្រា)

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៩/៤៤៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លាំង ចៀហាវ** (LIANG, CHIA-HAO) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ កើតថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩១ នៅទីក្រុង Taichung សាធារណរដ្ឋចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៩*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

៣៧៧. ១៩៣៣. ៤៥៤

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៩/៤៤៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **សេង ហ្វានចេង** (ZENG, FANCHENG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៦៩ នៅខេត្ត Hubei សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **សេង ចេង** (ZENG CHENG)។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មីនា ឆ្នាំ ២០១៩*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

៣៧. ១៩៣៣. ៤៥៣

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៩/៤៥០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ញាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្តល់សញ្ញាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក **លូ ដាវហ្គួយ** (LU, DAOGUI) ជនជាតិចិន សញ្ញាតិចិន កើតថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៧៥ នៅខេត្ត Fujian សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៩*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

៣៧. ១៩៣៣. ៤៥៤

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៩/៤៥១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហ៊ុង ចាន់វ៉េ** (HUNG, CHAN-WEI) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ កើតថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៧៥ នៅខេត្ត Fukien សាធារណរដ្ឋចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៩*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

៣៧.១៩៣.៤៥៥

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៩/៤៥៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងឯកឧត្តម **ឃួន សារៈមុនី** ជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០១៩
**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ចវកា.១៩០៣.៤៥៣

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៩/៤៥៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង និងផ្តល់ឋានៈមេធាវីរាជរដ្ឋាភិបាល ចំនួន ០៣រូប ៖

១- ឯកឧត្តម **លី ច័ន្ទតុលា** មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន

២- ឯកឧត្តម **ចេង ម៉េងហាប់** មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម **សាន់ ជួយ** មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០១៩

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ចរណ. ១៩០៣.៤៥៤

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៩/ ៤៥៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១**: តែងតាំងជារដ្ឋលេខាធិការ និងជាអនុរដ្ឋលេខាធិការ នៃក្រសួងចំនួន ០៤ ដូចមានខាងក្រោម ៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ម៉ុង គឹមហេង** | ជារដ្ឋលេខាធិការ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ២- លោកជំទាវ **សៅរី សុរិយា** | ជាអនុរដ្ឋលេខាធិការ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ៣- ឯកឧត្តម **សៅរី បណ្ឌិត** | ជាអនុរដ្ឋលេខាធិការ | ក្រសួងធនធានទឹក និងឧតុនិយម |
| ៤- ឯកឧត្តម **នៃ ឆាត់** | ជាអនុរដ្ឋលេខាធិការ | ក្រសួងសាធារណការ និងដឹកជញ្ជូន ។ |

**មាត្រា២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៩*

**ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ចរកា.១៩០៣.៤៥៥

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៩/៤៥៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១**: តែងតាំង និងផ្តល់ឋានៈជាទីប្រឹក្សារាជរដ្ឋាភិបាល ០៧រូប ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម **សៅ នី** មានឋានៈស្មើ រដ្ឋលេខាធិការ
២- ឯកឧត្តម **ស្រី ចាន់ថន** មានឋានៈស្មើ រដ្ឋលេខាធិការ
៣- លោកជំទាវ **សៅរី បូរាពេជ្រ** មានឋានៈស្មើ អនុរដ្ឋលេខាធិការ
៤- ឯកឧត្តម **សៅរី ឧត្តម** មានឋានៈស្មើ អនុរដ្ឋលេខាធិការ
៥- លោកជំទាវ **សៅរី មូនិកា** មានឋានៈស្មើ អនុរដ្ឋលេខាធិការ
៦- ឯកឧត្តម **ស ជីវសុិញ** មានឋានៈស្មើ អនុរដ្ឋលេខាធិការ
៧- ឯកឧត្តម **យ៉េង វណ្ណះតារា** មានឋានៈស្មើ អគ្គនាយក

**មាត្រា២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៩*

**ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ចារល.១៩០៣.៤៦០

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៩/៤៥៧

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្ទេរបញ្ចូលលោកវរសេនីយ៍ទោ **គាត ហ៊ុល** អត្តលេខ ១០១៧៦៤ នៃក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ ក្រសួងការពារជាតិ ទៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៦ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០១៩
**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

៣៩៧.១៩០៣.៤៦១

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៩/៤៥៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ដំឡើងឋានន្តរស័ក្តិឧត្តមអគ្គានុរក្សពន្ធនាគារ ដល់មន្ត្រីពន្ធនាគារ ចំនួន **១១ រូប** នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ៖

១- លោក **គង់ សំអុន** អត្តលេខ ០២៥៣ ពីវរអគ្គានុរក្ស ថ្នាក់លេខ ១ មកជាឧត្តមអគ្គានុរក្ស ថ្នាក់លេខ ៣

| ៤៣៨- | លោក ភោគ ភក្តី | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៣៩- | លោកស្រី អ៊ិត ម៉ីម៉ី | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៤០- | លោក សាវន ដានីន | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៤១- | លោកស្រី គុំ សុភាព | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៤២- | លោក នៅ វឌ្ឍនៈ | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៤៣- | លោក សង គឹមធី | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៤៤- | លោក ទឹម ផា | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៤៥- | លោកស្រី ងឹម វត្ថា | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៤៦- | លោកស្រី អោក ហួយ | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៤៧- | លោក ហ៊ាង ប៉េងហុង | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៤៨- | លោក ធឿន សុវណ្ណ | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៤៩- | លោកស្រី ទន់ គឹមស្រ៊ា | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៥០- | លោក ប៉ូ ដារ៉ែត | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៥១- | លោកស្រី កែវ ស្រីឡឹប | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៥២- | លោក ញឹម សុជាតិ្ធ | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៥៣- | លោកស្រី ផុន ផាន់នី | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៥៤- | លោក យឹន សុភី | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៥៥- | លោក ជា សុខនី | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៥៦- | លោកស្រី ហែម ចិន្តា | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៥៧- | លោក រៃ វុទ្ធ | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៥៨- | លោកស្រី អ៊ុំ សុរ៉ែ | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៥៩- | លោក ហួត រតនា | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៦០- | លោកស្រី ហ៊ុប ស្រីផ្សៀ | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |

| | |
|---|---|
| ៤៦១- លោក ផៃ សៅណា | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៦២- លោកស្រី វុន ធវី | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៦៣- លោក តាំ ផាត់យុត | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |
| ៤៦៤- លោក អ៊ុំ វឌ្ឍនៈ | មន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ៤ |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១២ រោច ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***អន្លែងទទួល***
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣៧៦ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនាឆ្នាំ ២០១៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការ បង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា១.** បំពាក់ មេដាយ**សហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនលោក Valeriu Arteni ភារធារីនៃប្រទេសរូម៉ានី ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការទំនាក់ទំនងការទូតរវាង ព្រះរាជាណាចក្រកម្ពុជា-រូម៉ានី កន្លងមក។

**មាត្រា២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ចន្ទ ១២ រោច ខែ ផល្គុន ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៧៧ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពី
# ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តម្លើងឋានន្តរស័ក្តិ និងថ្នាក់តាមកម្រិតសញ្ញាបត្រ ដល់មន្ត្រីរាជការចំនួន ៤៧ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១- លោក **គឹម ប៊ុនថន** | ពីវរមន្ត្រីថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ២- លោក **ម៉ឹង សុខលាភ** | ពីវរមន្ត្រីថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៣- លោក **ទូ សុធូ** | ពីវរមន្ត្រីថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៤- លោក **ប៉ែន សុភា** | ពីវរមន្ត្រីថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៥- លោក **ពៅ ណារិទ្ធ** | ពីវរមន្ត្រីថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៦- លោក **ឃន សុភ្លាមុធ** | ពីវរមន្ត្រីថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៧- លោក **ឈា សុរៈសិទ្ធ** | ពីវរមន្ត្រីថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៨- លោក **សុភ ភាន់ណារិទ្ធ** | ពីវរមន្ត្រីថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៩- លោក **សុខ សេរី** | ពីវរមន្ត្រីថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ១០- លោក **ហឿង រ័ត្នសុខា** | ពីវរមន្ត្រីថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ១១- លោកស្រី **តន សុមនា** | ពីវរមន្ត្រីថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ១២- លោក **ប៉េងហុង សុជាតិសិលា** | ពីវរមន្ត្រីថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ១៣- លោក **ជិន ពុទ្ធា** | ពីវរមន្ត្រីថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៤- លោក **ទុយឡាយ ឫទ្ធី** | ពីវរមន្ត្រីថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៥- លោក **ទី សឿន** | ពីវរមន្ត្រីថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៦- លោក **ភែង សុវណ្ណារ៉ាន់** | ពីវរមន្ត្រីថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៧- លោក **សួរ ណារ៉ូ** | ពីវរមន្ត្រីថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៨- លោក **អ៊ុត សំអាន** | ពីវរមន្ត្រីថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៩- លោក **ស៊ូ សុខជា** | ពីវរមន្ត្រីថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២០- លោក **ឡេង គីឈ័ង** | ពីវរមន្ត្រីថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២១- លោក **ថា ថាវរិទ្ធិ** | ពីវរមន្ត្រីថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២២- លោក **សោម សម្បត្តិ** | ពីវរមន្ត្រីថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២៣- លោក **ឃេ សុខឡេង** | ពីវរមន្ត្រីថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២៤- លោក **មឿង រី** | ពីវរមន្ត្រីថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២៥- លោក **យ៉ាញ់ ភ័ណា** | ពីវរមន្ត្រីថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២៦- លោក **ឌុច សុរ៉ែន** | ពីវរមន្ត្រីថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២៧- លោក **តុប វណ្ណៈ** | ពីវរមន្ត្រីថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២៨- លោក **ហេង ពិភាណ្ណារ៉ាត់** | ពីវរមន្ត្រីថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |

២៩- លោក **ម៉ៃ វណ្ណា** ពីវរមន្ត្រីថ្នាក់លេខ ៣ មកជា ថ្នាក់លេខ ២

៣០- លោក **កែវ រស្មី** ពីវរមន្ត្រីថ្នាក់លេខ ៣ មកជា ថ្នាក់លេខ ២

៣១- លោក **បាន សុវណ្ណតារា** ពីវរមន្ត្រីថ្នាក់លេខ ៣ មកជា ថ្នាក់លេខ ២

៣២- លោក **យូរ ស្រស់** ពីវរមន្ត្រីថ្នាក់លេខ ៣ មកជា ថ្នាក់លេខ ២

៣៣- លោក **ឱង សុទ្ធារិទ្ធិ** ពីវរមន្ត្រីថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣

៣៤- លោកស្រី **ប្រាជ្ញ សេរីសោភ័ណ** ពីវរមន្ត្រីថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣

៣៥- លោកស្រី **អ៊ុក ដានែត** ពីវរមន្ត្រីថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣

៣៦- លោក **សូរ សុភ័ក្រ្ត** ពីវរមន្ត្រីថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣

៣៧- លោក **ឡើ ខេង** ពីវរមន្ត្រីថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣

៣៨- លោកស្រី **ចាយ សុធាវី** ពីវរមន្ត្រីថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣

៣៩- លោកស្រី **គាំង រ៉ាវី** ពីវរមន្ត្រីថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣

៤០- លោកស្រី **រស់ សំបូរ** ពីវរមន្ត្រីថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣

៤១- លោកស្រី **ពេជ សុជាតា** ពីវរមន្ត្រីថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣

៤២- លោក **សួស សុខចាន់** ពីវរមន្ត្រីថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣

៤៣- លោក **យឹម មករា** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤

៤៤- លោក **ម៉ូវ វណ្ណតារ៉ា** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤

៤៥- លោក **ណុប ណារិន** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤

៤៦- លោក **ទ៉ូវ សំណាង** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤

៤៧- លោក **នៅ សុខធារិទ្ធ** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤

**មាត្រា ២ .-** តម្លើងឋានន្តរស័ក្តិ និងថ្នាក់តាមកម្រិតសញ្ញាបត្រ ដល់មន្ត្រីរាជការចំនួន ៣៥ រូប នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដូចមានរាយនាមខាងក្រោម ៖

១- លោក **គៀង ហាក់** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១

២- លោក **ចៅ ប្រាជ្ញសុវណ្ណា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១

៣- លោក **អ៊ុក នរឫទ្ធិ** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១

៤- លោក **យឹម ចំរើន** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១

៥- លោក **ចៅ ឡង់ឌី** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១

៦- លោក **ប៊ី ជីវ័នតារា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១

៧- លោក **មៀង សុថា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ៣ មកជា ថ្នាក់លេខ ២

៨- លោក **តូន តូម៉ូនីរតន៍** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ៣ មកជា ថ្នាក់លេខ ២

៩- លោកស្រី **ទួន មន្ថា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ៣ មកជា ថ្នាក់លេខ ២

១០- លោក **ប៊ុន ឡុង** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ៣ មកជា ថ្នាក់លេខ ២

១១- លោក ម៉ែន មុឆនី ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ៣ មកជា ថ្នាក់លេខ ២
១២- លោក ចូម សុិទ្ធី ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ៣ មកជា ថ្នាក់លេខ ២
១៣- លោក ដួង សារ៉ាត់ ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ៣ មកជា ថ្នាក់លេខ ២
១៤- លោក ស៊ិម ចន្ថា ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ៣ មកជា ថ្នាក់លេខ ២
១៥- លោក ម៉ុក សុផាន់ណារ៉ា ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ៣ មកជា ថ្នាក់លេខ ២
១៦- លោក អ៊ុន ប៊ុនថា ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣
១៧- លោក សេក សំខេមរា ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣
១៨- លោក ហ៊ឿ អំសាន្ត ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣
១៩- លោក អ៊ុក វណ្ណដារ៉ែត ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣
២០- លោក អ៊ឹង ណាង ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣
២១- លោក ហ៊ាង ម៉ាប់ ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣
២២- លោក លី សុភា ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣
២៣- លោក គឹម ពិសិដ្ឋ ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣
២៤- លោក ម៉េង ហ៊ាង ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣
២៥- លោក ស៊ី រ័ត្នមុនី ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣
២៦- លោក សាន ស៊ីចន្ថា ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១
មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
២៧- លោក សន តីរម្យ ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១
មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
២៨- លោក ទេព ចែ៉តពិសិដ្ឋ ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១
មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
២៩- លោក គិត វិសិដ្ឋអញ្ញា ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១
មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
៣០- លោក សៅ អ៊ាម ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១
មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
៣១- លោក សុខ ម៉ារ៉ា ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១
មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
៣២- លោក និត សាណែត ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១
មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
៣៣- លោកស្រី ហ៊ឿ សុខុម ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១
មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
៣៤- លោក អ៊ុច ពុទ្ធា ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១
មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

៣៥- លោក **ហ៊ី ទណ្ណា:** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១
មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១២ រោច ខែ ផល្គុន ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***អន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៧៨ អនក្រ.តត

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១**..បំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនមន្ត្រីអង្គការសកម្មភាពកុមារដើម្បីអភិវឌ្ឍ ចំនួន៤រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងអគារសិក្សា១ខ្នង មាន៤បន្ទប់ នៅសាលាបឋមសិក្សាឯកភ្នំ ឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង ចំណាយអស់ថវិកាសរុបចំនួន ៣៨ ៨៨៦ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-លោក | ដាំងខិន | វាត | ( Mr.DUNCAN WARD ) |
| ២-អ្នកស្រី | វិនឌី | ត្រូវ | ( Ms.WENDY TROW ) |
| ៣-លោក | ធី | ប៊ុនរិទ្ធិ | ( Mr.THY BUNRITH ) |
| ៤-លោក | ថម | ហែ្សន | ( Mr.TOM HANDS ) |

**មាត្រា២**..រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ចន្ទ ១២ រោច ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៥៧....សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សា និងដោះស្រាយបញ្ហា បាក់ច្រាំងទន្លេបាសាក់-ទន្លេហ៊្វ និងព្រែកជ្រៃធំ-ព្រែកប៊ិញឃី នៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២១៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាគណៈអភិបាលខេត្តក្រុមប្រឹក្សាគណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សា និងដោះស្រាយបញ្ហាបាក់ច្រាំងទន្លេបាសាក់-ទន្លេហ៊្វ និងព្រែកជ្រៃធំ-ព្រែកប៊ិញឃី នៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ដែលមានសមាសភាពដូចខាងក្រោម ៖

១. ឯកឧត្តម **ឡាំ ជា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ប្រធាន
២. តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន
៣. តំណាងគណៈកម្មាធិការចំរុះកិច្ចការព្រំដែន អនុប្រធាន
៤. ឯកឧត្តម **ម៉ៅ ភិរុណ** អភិបាល នៃគណៈអភិបាលខេត្តកណ្ដាល អនុប្រធានអចិន្ត្រៃយ៍
៥. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
៦. តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
៧. តំណាងក្រសួងធនធានទឹក និងឧតុនិយម សមាជិក
៨. ឯកឧត្តម **ច្រាក់ សំអឿន** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល សមាជិក
៩. ឯកឧត្តម នាយឧត្តមសេនីយ៍ **ហ៊ូ សាគុណា** អគ្គស្នងការរងនគរបាលជាតិ សមាជិក
១០. ឯកឧត្តម **សួស ច្រាថ្លា** អគ្គនាយករងទទួលបន្ទុកជាប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត សមាជិក

**ប្រការ ២.-**

គណៈកម្មការខាងលើនេះ មានតួនាទី ភារកិច្ចដូចខាងក្រោម៖

- សិក្សា ស្រាវជ្រាវរកមូលហេតុ និងផលប៉ះពាល់នៃការបាក់ច្រាំងទន្លេបាសាក់-ទន្លេហ៊ូវ និងព្រែកជ្រៃធំ-ព្រែកប៊ិញយី តាមបណ្ដោយព្រំដែនកម្ពុជា-វៀតណាម
- ពិភាក្សា និងរកដំណោះស្រាយលើបញ្ហាបាក់ច្រាំងទន្លេបាសាក់-ទន្លេហ៊ូវ និងព្រែកជ្រៃធំ-ព្រែកប៊ិញយី
- ចាត់វិធានការសមស្របនៅក្នុងការបង្ការ និងទប់ស្កាត់ការបាក់ច្រាំងនេះ
- សម្របសម្រួល និងប្រជុំពិភាក្សាជាមួយភាគីវៀតណាមដើម្បីរិះរកមធ្យោបាយសមស្របនៅក្នុងការដោះស្រាយបញ្ហាបាក់ច្រាំងនេះ
- រៀបចំគម្រោងផែនការសកម្មភាព បង្ការ ទប់ស្កាត់ និងដើម្បីដោះស្រាយបញ្ហាបាក់ច្រាំងនេះ
- រៀបចំគម្រោងថវិកាចំណាយលម្អិត សម្រាប់សាងសង់ច្រាំងទន្លេ និងព្រែកនៅទីតាំងបាក់ច្រាំងតាមស្ថានភាពជាក់ស្ដែង ដើម្បីដាក់ជូនរាជរដ្ឋាភិបាល
- រៀបចំរបាយការណ៍ស្ដីពីលទ្ធផលសម្រេចបាន និងវឌ្ឍនភាពការងារជូនប្រមុខរាជរដ្ឋាភិបាល តាមរយៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**ប្រការ ៣.-**

ប្រធានគណៈកម្មការអន្តរក្រសួងត្រូវរាយការណ៍សុំយោបល់ដឹកនាំជាប្រចាំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ប្រធានគណៈកម្មការអន្តរក្រសួងមានសិទ្ធិកោះអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួមកិច្ចប្រជុំពិភាក្សា ដើម្បីស្វែងរកដំណោះស្រាយទាក់ទងនឹងបញ្ហាបាក់ច្រាំងនេះ តាមការចាំបាច់។

អនុប្រធាន និងសមាជិកគណៈកម្មការអន្តរក្រសួងត្រូវបំពេញការងារក្រោមការចាត់ចែងរបស់ប្រធានគណៈកម្មការអន្តរក្រសួង។

**ប្រការ ៤.-**

គណៈកម្មការអន្តរក្រសួងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ដើម្បីចាត់ចែងការងាររបស់ខ្លួន។

ថវិកាចំណាយ មធ្យោបាយ និងសម្ភារសម្រាប់បំពេញបេសកកម្មការងាររបស់ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការអន្តរក្រសួង ជាបន្ទុករបស់ក្រសួងស្ថាប័នសាមី។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការចំរុះកិច្ចការព្រំដែន រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៥ កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ មេសា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៦០ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួងសម្រាប់រៀបចំពិធីតភ្ជាប់មុខតំណាស្ពានមិត្តភាពកម្ពុជា-ថៃ (ស្ទឹងបត់-បានណាងអៀន) ពិធីបើកការដ្ឋានសាងសង់អគារច្រកទ្វារព្រំដែនស្ទឹងបត់ និងពិធីប្រគល់-ទទួលក្បាលរថភ្លើង (DMU)

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

## សម្រេច

**ប្រការ១ .–**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំពិធីតភ្ជាប់មុខតំណាស្ពានមិត្តភាពកម្ពុជា-ថៃ (ស្ទឹងបត់-បានណាងអៀន) ពិធីបើកការដ្ឋានសាងសង់អគារច្រកទ្វារព្រំដែនស្ទឹងបត់ ពិធីប្រគល់-ទទួលក្បាលរថភ្លើង (DMU) និងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីប្រតិបត្តិការរួមគ្នាការដឹកជញ្ជូនផ្លូវដែកឆ្លងកាត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជានិងព្រះរាជាណាចក្រថៃ ដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ប្រធាន



៩៩

| | | |
|---|---|---|
| ២- ឯកឧត្តម **យូ ស៊ុនឡុង** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៣- ឯកឧត្តម **តូច ចាន់កុសល** | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | អនុប្រធានប្រចាំការ |
| ៤- ឯកឧត្តម **សក់ សេដ្ឋា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៥- លោកជំទាវ **អ៊ិត សោភា** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៦- ឯកឧត្តម **នីយ ឿន** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៧- ឯកឧត្តម **ហ៊ាន សាហ៊ីប** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៨- ឯកឧត្តម នាយឧត្តមសេនីយ៍ **ខង្ស ពិសេន** | អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ | អនុប្រធាន |
| ៩- ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត **នេត សាវឿន** | អគ្គស្នងការនគរបាលជាតិ | អនុប្រធាន |
| ១០- ឯកឧត្តម នាយឧត្តមសេនីយ៍ **សៅ សុខា** | អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | អនុប្រធាន |
| ១១- ឯកឧត្តម នាយឧត្តមសេនីយ៍ **ហ៊ីង ប៊ុនហៀង** | អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការនៃបញ្ជាការដ្ឋានកងអង្គរក្ស | អនុប្រធាន |
| ១២- ឯកឧត្តម នាយឧត្តមសេនីយ៍ **គៀត ច័ន្ទថារិទ្ធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | អនុប្រធាន |
| ១៣- ឯកឧត្តម **ហ៊ុន ស៊ីថា** | នាយករងខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី | សមាជិក |
| ១៤-លោកជំទាវ **សុខឡេង ម៉ូរ៉ា** | នាយិកាពិធីការសម្តេចតេជោនាយករដ្ឋមន្ត្រី | សមាជិកា |
| ១៥- ឯកឧត្តម **ស្នួច ហេង** | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១៦- ឯកឧត្តម **សុខុម គគចន្ទមុនី** | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១៧- ឯកឧត្តម **នាង ផាត** | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ១៨- ឯកឧត្តម **គុណ ញឹម** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ១៩- ឯកឧត្តម នាយឧត្តមសេនីយ៍ **ខេង សាម៉េត** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ២០- ឯកឧត្តម **ឃិត បុណ្ណារ៉ា** | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ២១- ឯកឧត្តម **លី ប៊ូរិន** | អនុរដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ២២- ឯកឧត្តម **ស្លួន បឋរ** | អភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ | សមាជិក |
| ២៣- ឯកឧត្តម **អ៊ិត សីលា** | អគ្គលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២៤- ឯកឧត្តម **ឈិន កេតនា** | អនុប្រធានអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការ នៃគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ | សមាជិក |
| ២៥- ឯកឧត្តម **ម៉ាស៊ីម សុរិយា** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ២៦- ឯកឧត្តម **ហេង រត្នពិសិដ្ឋ** | អគ្គនាយក នៃអគ្គនាយកដ្ឋានសាធារណការ | សមាជិក |
| ២៧- ឯកឧត្តម **នូ ចឡុនៈ** | អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស | សមាជិក |
| ២៨- ឯកឧត្តម **ហេង រតនា** | អគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (ស៊ីម៉ាក់) | សមាជិក |

| | | |
|---|---|---|
| ២៩- ឯកឧត្តម **ឯក សំអូន** | មេបញ្ជាការយោធភូមិភាគទី៥ | សមាជិក |
| ៣០- លោក **សុខ ខឿន** | ប្រធាននាយកដ្ឋានព្រំដែន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៣១- លោក **សាន ស៊ានហូ** | អភិបាល នៃគណៈអភិបាលក្រុងប៉ោយប៉ែត | សមាជិក |
| ៣២- លោក **ពេជ្រ ចណ្ណារ៉ា** | ប្រធានការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ | សមាជិក។ |

**ប្រការ២.-**

គណៈកម្មការនេះមានភារកិច្ចទទួលខុសត្រូវរួមក្នុងការដឹកនាំគ្រប់គ្រងចាត់ចែងនិងសហការជាមួយគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ក្រសួង-ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ និងសមត្ថកិច្ចពាក់ព័ន្ធ ព្រមទាំងទំនាក់ទំនងសហការសម្របសម្រួល ជាមួយភាគីថៃ ស្ថានទូត និងអាជ្ញាធរពាក់ព័ន្ធរបស់ព្រះរាជាណាចក្រថៃ ដើម្បីសហការរៀបចំពិធីចាក់បេតុងតភ្ជាប់មុខតំណាស្ពានមិត្តភាពកម្ពុជា-ថៃ (ស្ទឹងបត់-បានណងអៀន) ពិធីបើកការដ្ឋានសាងសង់អគារច្រកទ្វារព្រំដែនស្ទឹងបត់ ពិធីប្រគល់-ទទួលក្បាលរថភ្លើង (DMU) និងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីប្រតិបត្តិការរួមគ្នាការដឹកជញ្ជូនផ្លូវដែកឆ្លងកាត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជានិងព្រះរាជាណាចក្រថៃ ឱ្យបានរលូន សុវត្ថិភាព ប្រសិទ្ធភាពខ្ពស់ និងទទួលបានជោគជ័យ។

គណៈកម្មការនេះ អាចបង្កើតអនុគណៈកម្មការមួយចំនួន តាមការចាំបាច់។

**ប្រការ៣.-**

គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រាក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីបំពេញភារកិច្ចនិងការងារប្រចាំថ្ងៃ។

**ប្រការ៤.-**

អនុប្រធាន និងសមាជិកនៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ប្រធានគណៈកម្មការនេះ មានសិទ្ធិអញ្ជើញតំណាងពីក្រសួង-ស្ថាប័ននានា ឱ្យចូលរួមពិនិត្យ ផ្តល់យោបល់ ក្នុងករណីចាំបាច់។

**ប្រការ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ។

ថ្ងៃសុក្រ ១៥ កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦១ សសរ

**សេចក្តីសម្រេច**
**ស្តីពី**
**ការបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តព្រះសីហនុ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ១ .-**

ត្រូវបានបំពេញបន្ថែម **ឯកឧត្តម លូ គឹមឈុន** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយក កំពង់ផែស្វយ័តក្រុងព្រះសីហនុ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ជាសមាជិកក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋាន ខេត្តព្រះសីហនុ ។

**ប្រការ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋបាលខេត្តព្រះសីហនុ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ៤ រោច ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០១៩

**តប.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

<u>កន្លែងទទួល:</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ**...៦៧...ស.សរ

## សេចក្ដីសម្រេច
## ស្ដីពី
## ការបំពេញបន្ថែម និងកែសម្រួលសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តស្ទឹងត្រែង

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ១ .-**

ត្រូវបានបំពេញបន្ថែម **ឯកឧត្ដម ហេង វ៉ាន់** ទីប្រឹក្សា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ខេត្តស្ទឹងត្រែង ។

**ប្រការ២ .-**

ត្រូវបានកែសម្រួល **ឯកឧត្តម ញ៉ន ស៊ី** ទីប្រឹក្សាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និសំណង់ ពីសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ខេត្តស្ទឹងត្រែង ដោយរក្សាទុកជាសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ខេត្តស្វាយរៀង ។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និសំណង់ រដ្ឋបាលខេត្តស្ទឹងត្រែង និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ និងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ៤ រោច ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០១៩

**គប.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

<u>កន្លែងទទួល:</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៣ សសរ

## សេចក្តីសម្រេច
## ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## <u>សម្រេច</u>

**ប្រការ ១** : ត្រូវបានផ្ទេរសិទ្ធិជូនសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវអញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា ទៅចូលរួមវេទិកាខ្សែក្រវ៉ាត់ និងផ្លូវ លើកទី២ នៅទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន ចាប់ពីថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៩ រហូតដល់ពេលសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន អភិបាលរាជធានី អភិបាលគ្រប់ខេត្ត និងសម្តេចក្រឡាហោម **ស ខេង** ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ៕

ថ្ងៃព្រហស្បតិ៍ ៦ រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល**</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០៤០...........សហវ.....

## សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាពគណៈកម្មាធិការអនុវត្តការងារទិញ សាងសង់ ជួសជុល បំពាក់សម្ភារ ឧបករណ៍ គ្រឿងសង្ហារឹម និងអចលនទ្រព្យរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨អនក្រ.បកចុះថ្ងៃទី១៦ខែតុលាឆ្នាំ២០១៣ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៣៨១ សហវ.ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញប្រកាសលេខ ៩៥៨ សហវ.ប្រក.អគរ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលការប្រើប្រាស់ប្រាក់រង្វាន់នៃចំណូលប្រមូលដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- សេចក្តីសម្រេចលេខ ០០១ សហវ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការអនុវត្តការងារទិញ សាងសង់ ជួសជុល បំពាក់សម្ភារ ឧបករណ៍ គ្រឿងសង្ហារឹម និងអចលនទ្រព្យ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១.-**

ត្រូវបានកែសម្រួលសមាសភាពគណៈកម្មាធិការអនុវត្តការងារទិញ សាងសង់ ជួសជុល បំពាក់សម្ភារ ឧបករណ៍ គ្រឿងសង្ហារឹម និងអចលនទ្រព្យរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដូចខាងក្រោម÷

១. ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធាន

២. ឯកឧត្តម **គុណ ញឹម** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អនុប្រធាន

៣. ឯកឧត្តម **គីម សុតះ** អនុរដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៤. ឯកឧត្តម **មាស សុខសេនសាន** អគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៥. លោកស្រី **ហេង សំអូន** អគ្គនាយករងនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក

៦. លោក **ម៉ូ ទណ្ណា** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក ។

**ប្រការ ២.-**

គណៈកម្មាធិការក្នុងប្រការ ១ ខាងលើ មានភារកិច្ចដូចខាងក្រោម÷

១. ប្រើប្រាស់ប្រាក់រង្វាន់ ០.៥% និងប្រាក់រង្វាន់ ១% របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

២. ត្រួតពិនិត្យរាល់កិច្ចលទ្ធកម្ម និងមានសិទ្ធិសម្រេចលើរបាយការណ៍វាយតម្លៃប្រគល់កិច្ចសន្យា និង អនុម័តកិច្ចសន្យា

៣. ពិនិត្យឡើងវិញលើឯកសារដេញថ្លៃ ពិគ្រោះថ្លៃ ចរចាថ្លៃ ដើម្បីឱ្យការអនុវត្តសមស្របតាមវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ

៤. ពិនិត្យ និងអនុម័តលើរបាយការណ៍វាយតម្លៃប្រគល់កិច្ចសន្យា ដែលរៀបចំឡើងដោយក្រុមការងារ អនុវត្តការងារលទ្ធកម្មរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

៥. ចុះពិនិត្យ និងវាយតម្លៃការអនុវត្តការងារសាងសង់នៅតាមការដ្ឋាន ព្រមទាំងការអនុវត្តការងារ ពាក់ព័ន្ធផ្សេងទៀត

៦. ធ្វើរបាយការណ៍ជាប្រចាំស្តីពីលទ្ធផលការងាររបស់ខ្លួន ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជ្រាបជាព័ត៌មាន ឬពិនិត្យជាយថាហេតុ។

**ប្រការ ៣.-**

ត្រូវបានកែសម្រួលសមាសភាពក្រុមការងារអនុវត្តការងារលទ្ធកម្មរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករ កម្ពុជា ដែលជាសេនាធិការឱ្យគណៈកម្មាធិការលទ្ធកម្មក្នុងប្រការ ១ ខាងលើ ដូចខាងក្រោម÷

១. លោក **សុខ ឡើ** អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ប្រធាន

| | | |
|---|---|---|
| ២. លោកស្រី **ឆាន់ ទីរីយ៉ា** | ប្រធានអង្គភាពលទ្ធកម្ម<br>នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. លោក **គង់ សុខផល្លាគុណា** | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក<br>នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ៤. លោក **ជា សំអុន** | ប្រធានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ<br>នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ៥. លោក **ព្រឿង ប្រុណរិត** | ប្រធានការិយាល័យគណនេយ្យនៃនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ<br>អគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៦. លោកស្រី **ឆន់ ពុទ្ធីមាន** | អនុប្រធានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ<br>នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |

**ប្រការ ៤.-**

ក្រុមការងារអនុវត្តការងារលទ្ធកម្មរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានភារកិច្ចបន្ថែមលើភារកិច្ចនៃមុខងារបច្ចុប្បន្នដូចខាងក្រោម÷

១. ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មាធិការ ក្នុងការរៀបចំឯកសារពាក់ព័ន្ធក្នុងការដេញថ្លៃ និងរបាយការណ៍ ដើម្បីដាក់ជូនគណៈកម្មាធិការពិនិត្យ និងសម្រេច

២.ទទួលខុសត្រូវអនុវត្តកិច្ចលទ្ធកម្ម និងរៀបចំឯកសារលទ្ធកម្មសមស្របតាមគោលការណ៍ណែនាំរបស់គណៈកម្មាធិការ

៣.ធានាថារាល់របាយការណ៍សំខាន់ៗត្រូវរៀបចំទាន់ពេលវេលា

៤.ធានាថារាល់ឯកសារកត់ត្រាទាំងអស់ពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មត្រូវបានចងក្រង និងទុកដាក់បានត្រឹមត្រូវ

៥.ទាក់ទងដោយផ្ទាល់ ឬផ្តល់ព័ត៌មានផ្ទាល់អំពីកិច្ចលទ្ធកម្មដល់អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ អ្នកទទួលការ និងទីប្រឹក្សា

៦.ចាត់ចែង និងត្រួតពិនិត្យការងារអនុវត្តកិច្ចលទ្ធកម្ម

៧.រៀបចំតារាងបញ្ជាក់លក្ខណៈបច្ចេកទេស តារាងទំហំការងារ និងលក្ខខណ្ឌការងារ

៨.ជ្រើសរើសលក្ខណៈអនុវត្តកិច្ចសន្យា ដើម្បីបញ្ចូលក្នុងឯកសារដេញថ្លៃ

៩.បញ្ជាក់លើភាពឆ្លើយតបត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងតម្លៃនៃសំណើដេញថ្លៃដែលបានទទួល

១០.ត្រួតពិនិត្យ វាយតម្លៃការអនុវត្តកិច្ចសន្យារបស់អ្នកផ្គត់ផ្គង់ អ្នកទទួលការ និងទីប្រឹក្សា

១១.រៀបចំកែលម្អសេចក្តីជូនដំណឹងទូទៅអំពីកិច្ចលទ្ធកម្ម និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងការបញ្ជាក់អំពីការចូលរួមដែលទទួលបានពីការផ្សព្វផ្សាយសេចក្តីជូនដំណឹងខាងលើ

១២.កំណត់បរិមាណទំនិញ សំណង់ និងសេវាសម្រាប់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

១៣.រៀបចំឯកសារដេញថ្លៃសម្រាប់ប្រភេទលទ្ធកម្មនីមួយៗ ផ្អែកតាមគំរូឯកសារដេញថ្លៃដែលកំណត់ដោយគណៈកម្មាធិការ

១៤.រៀបចំ និងផ្សព្វផ្សាយសេចក្តីជូនដំណឹងអំពីកិច្ចលទ្ធកម្មនីមួយៗ

១៥.បញ្ជូនឯកសារដេញថ្លៃ (ករណីលើសសិទ្ធិសម្រេច) ទៅគណៈកម្មាធិការ

១៦.លក់ឯកសារដេញថ្លៃជូនអ្នកដេញថ្លៃទាំងអស់ ដែលមានបំណងចូលរួម

១៧.ទទួលសំណើដេញថ្លៃ និងបកស្រាយបំភ្លឺចំពោះអ្នកដេញថ្លៃទាំងអស់ក្នុងករណីមានសំណួរពាក់ព័ន្ធនឹងការដេញថ្លៃក្នុងរយៈពេលដេញថ្លៃ

១៨.ត្រូវធានាថា ទីកន្លែងបើកសំណើដេញថ្លៃសមរម្យ និងមានសណ្តាប់ធ្នាប់

១៩.រៀបចំទុកដាក់សំណើដេញថ្លៃដែលបានទទួលឱ្យបានត្រឹមត្រូវ មានសុវត្ថិភាព និងត្រូវគ្រប់គ្រងឯកសារឬលិខិតស្នាមទាំងអស់មុន និងក្រោយចុះកិច្ចសន្យា

២០.រៀបចំសំណើដេញថ្លៃជាសាធារណៈដោយមានការត្រួតពិនិត្យពីគណៈកម្មាធិការ

២១.ពិនិត្យមើលលិខិតធានាប្រាក់កក់ធានាដេញថ្លៃ ដើម្បីរក្សាទុកឱ្យមានសុវត្ថិភាព និងកត់ត្រាចំនួនទឹកប្រាក់ និងសុពលភាពលិខិតធានាប្រាក់កក់ធានាការដេញថ្លៃ។ ចំពោះលិខិតធានាប្រាក់កក់ធានាដេញថ្លៃនេះមិនត្រូវអស់សុពលភាពមុនសេចក្តីជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យា។ ករណីអស់សុពលភាពត្រូវឱ្យអ្នកដេញថ្លៃពន្យារពេលសុពលភាពលិខិតធានាប្រាក់កក់នេះ

២២.វាយតម្លៃបឋមលើសំណើដេញថ្លៃដែលទទួលបាន ក្រោមការដឹកនាំរបស់គណៈកម្មាធិការ

២៣.ត្រួតពិនិត្យការទូទាត់ឱ្យបានត្រឹមត្រូវតាមកិច្ចសន្យាជូនអ្នកផ្គត់ផ្គង់ អ្នកទទួលការ ឬទីប្រឹក្សា។

**ប្រការ ៥.-**

សមាជិកនៃគណៈកម្មាធិការអនុវត្តការងារទិញ សាងសង់ ជួសជុល បំពាក់សម្ភារ ឧបករណ៍ គ្រឿងសង្ហារឹម និងអចលនទ្រព្យរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការ។

សមាជិកនៃក្រុមការងារអនុវត្តការងារលទ្ធកម្ម របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារអនុវត្តការងារលទ្ធកម្ម។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៧.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ប្រតិភូរាជរដ្ឋាភិបាល អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចប្រការ ១ និងប្រការ ៣ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ព្រហស្បតិ៍ ៣ កើត ខែ ចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០១៩

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៦២ សហវ.

**សារាចរណែនាំ**

**ស្តីពី**

**កិច្ចបញ្ជិកាគណនេយ្យលើការផ្តល់ឧបត្ថម្ភធនរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល**

កន្លងមករាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល។ ក្នុងគោលដៅកំណែទម្រង់ និងពន្លឿនការផ្តល់ឧបត្ថម្ភធនពីថវិការដ្ឋស្របតាមផែនការសកម្មភាពដែលគ្រឹះស្ថានសាធារណៈរដ្ឋបាលបានគ្រោងទុក ដោយអនុញ្ញាតឱ្យអគ្គនាយក នាយក សាកលវិទ្យាធិការ និងប្រធានគ្រឹះស្ថានសាធារណៈរដ្ឋបាលជាអាណាប័កផ្ទេរសិទ្ធដោយស្វ័យប្រវត្តិ និងអាចស្នើសុំឧបត្ថម្ភធន ដូចមាត្រា៩ នៃអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ដែលបានកំណត់ថា "រតនាគារជាតិត្រូវផ្ទេរថវិកាស្មើនឹង ១/៤ នៃថវិកាឧបត្ថម្ភធនប្រចាំឆ្នាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ចូលគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅរតនាគារជាតិ" ដើម្បីឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលមានលក្ខណៈងាយស្រួល និងឆាប់រហ័សលើការចំណាយសម្រាប់ដំណើរការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចេញសារាចរណែនាំសម្រាប់អនុវត្តដូចតទៅ÷

**I. ការផ្តល់ឧបត្ថម្ភធនសម្រាប់ដំណើរការត្រីមាសទី១÷**

ពេលផ្តល់ និងទទួលថវិកាបំពេញបន្ថែមសមតុល្យនៃគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល រតនាគារថ្នាក់កណ្តាល ឬ រតនាគាររាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវកត់ត្រាដូចខាងក្រោម÷

**ក. កិច្ចបញ្ជិកាគណនេយ្យរបស់រតនាគារថ្នាក់កណ្តាល ឬ រតនាគាររាជធានី ខេត្ត÷**

ឥណពន្ធ គណនី បុរេប្រទានបន្ថែមសមតុល្យនៃគណនីប្រាក់បញ្ញើ (លេខ ១៥០៥៧)

ឥណទាន គណនី ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ជាប្រាក់រៀល (លេខ ៤៤០៥១)។

សក្ខីបត្រ÷

- សៀវភៅថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល (ច្បាប់ថតចម្លង)
- លិខិតរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្នើទៅអគ្គនាយកដ្ឋានរតនាគារជាតិសុំផ្តល់ឧបត្ថម្ភធន
- លិខិតជូនដំណឹងឥណទានរបស់រតនាគារថ្នាក់កណ្តាល ឬ របស់រតនាគាររាជធានី ខេត្ត
- សលាកបត្រចុះលេខនា។

**ខ. កិច្ចបញ្ជិការបស់គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល÷**

ឥណពន្ធ គណនី ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល នៅរតនាគារ ជាប្រាក់រៀល (លេខ ១២០៥១)

ឥណទាន គណនី បុរេប្រទានបានទទួល (លេខ ១១០៨)។

សក្ខីបត្រ÷

- សៀវភៅថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល (ច្បាប់ថតចម្លង)
- លិខិតរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្នើទៅអគ្គនាយកដ្ឋានរតនាគារជាតិសុំផ្តល់ឧបត្ថម្ភធន

-លិខិតជូនដំណឹងឥណទានរបស់រតនាគារថ្នាក់កណ្តាល ឬ រតនាគាររាជធានី ខេត្ត

-សលាកបត្រចុះលេខនា។

**II. ការទូទាត់បុរេប្រទានបន្ថែមសមតុល្យដែលគ្រឹះស្ថានសាធារណៈរដ្ឋបាលបានទទួល÷**

**១. សម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមានគណនីប្រាក់បញ្ញើនៅរតនាគារថ្នាក់កណ្តាល÷**

**១.១.** ក្រោយពីបានទទួលអាណត្តិបើកប្រាក់ផ្តល់ឧបត្ថម្ភធនពីថវិការដ្ឋ ត្រូវកត់ត្រាដូចខាងក្រោម÷

**ក. កិច្ចបញ្ជិកាគណនេយ្យរបស់រតនាគារថ្នាក់កណ្តាល÷**

ឥណពន្ធ គណនី ឧបត្ថម្ភធនជាហិរញ្ញវត្ថុដល់គ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល (លេខ ៦៥០៣១)

ឥណទាន គណនី ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ជាប្រាក់រៀល (លេខ ៤៤០៥១)។

សក្ខីបត្រ÷

-អាណត្តិបើកប្រាក់ផ្តល់ឧបត្ថម្ភធនពីថវិការដ្ឋ

-លិខិតជូនដំណឹងឥណទានរបស់រតនាគារថ្នាក់កណ្តាល

-សលាកបត្រចុះលេខនា។

**ខ. កិច្ចបញ្ជិការបស់គណនេយ្យកររប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល ÷**

ឥណពន្ធ គណនី ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល នៅរតនាគារ ជាប្រាក់រៀល (លេខ ១២០៥១)

ឥណទាន គណនី ឧបត្ថម្ភធនពីក្រសួង ស្ថាប័ន (លេខ ៧៥០១១)។

សក្ខីបត្រ÷

-អាណត្តិបើកប្រាក់ផ្តល់ឧបត្ថម្ភធនពីថវិការដ្ឋ (ច្បាប់ថតចម្លង)

-លិខិតជូនដំណឹងឥណទានរបស់រតនាគារថ្នាក់កណ្តាល

-សលាកបត្រចុះលេខនា។

**១.២.** ក្រោយបានទទួលទឹកប្រាក់ផ្តល់ឧបត្ថម្ភធនពីថវិការដ្ឋ រតនាគារថ្នាក់កណ្តាលត្រូវកាត់សមតុល្យគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងជម្រះសមតុល្យគណនីបុរេប្រទានបន្ថែមសមតុល្យនៃគណនីប្រាក់បញ្ញើដោយស្វ័យប្រវត្តិ។ ការកត់ត្រាដូចខាងក្រោម÷

**ក. កិច្ចបញ្ជិកាគណនេយ្យរបស់រតនាគារថ្នាក់កណ្តាល÷**

ឥណពន្ធ គណនី ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ជាប្រាក់រៀល (លេខ ៤៤០៥១)

ឥណទាន គណនី បុរេប្រទានបន្ថែមសមតុល្យនៃគណនីប្រាក់បញ្ញើ (លេខ ១៥០៥៧)។

សក្ខីបត្រ÷

- លិខិតរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលស្នើទៅអគ្គនាយកដ្ឋានរតនាគារជាតិសុំផ្តល់ឧបត្ថម្ភធន (ច្បាប់ថតចម្លង)

-លិខិតជូនដំណឹងឥណពន្ធរបស់រតនាគារថ្នាក់កណ្តាល

-សលាកបត្រចុះលេខនា។

**ខ. កិច្ចបញ្ជិការបស់គណនេយ្យកររប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល ÷**

ឥណពន្ធ គណនី បុរេប្រទានបានទទួល (លេខ ១១០៨)

ឥណទាន គណនី ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល នៅរតនាគារ ជាប្រាក់រៀល (លេខ ១២០៥១)។

សក្ខីបត្រ÷

-លិខិតជូនដំណឹងឥណពន្ធរបស់រតនាគារថ្នាក់កណ្តាល

-សលាកបត្រចុះលេខនា។

**២. សម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមានគណនីប្រាក់បញ្ញើនៅរតនាគាររាជធានី ខេត្ត÷**

**២.១.** ក្រោយពីបានទទួលអាណត្តិបើកប្រាក់ផ្តល់ឧបត្ថម្ភធនពីថវិការដ្ឋ កត់ត្រាដូចខាងក្រោម÷

**កិច្ចបញ្ជិកាគណនេយ្យរបស់រតនាគារថ្នាក់កណ្តាល÷**

ឥណពន្ធ គណនី ឧបត្ថម្ភធនជាហិរញ្ញវត្ថុដល់គ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល (លេខ ៦៥០៣១)

ឥណទាន គណនី ឥណទាយីផ្សេងៗ (លេខ ៤៧០៧៨)។

សក្ខីបត្រ÷

-អាណត្តិបើកប្រាក់ផ្តល់ឧបត្ថម្ភធនពីថវិការដ្ឋ

-លិខិតជូនដំណឹងឥណទានរបស់រតនាគារថ្នាក់កណ្តាល

-សលាកបត្រចុះលេខនា។

**២.២.** ការផ្ទេរវត្តលេខផ្តល់ឧបត្ថម្ភធនពីរតនាគារថ្នាក់កណ្តាល ទៅគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅរតនាគាររាជធានី ខេត្ត ត្រូវកត់ត្រា÷

**ក. កិច្ចបញ្ជិកាគណនេយ្យរបស់រតនាគារថ្នាក់កណ្តាល÷**

ឥណពន្ធ គណនី ឥណទាយីផ្សេងៗ (លេខ ៤៧០៧៨)

ឥណទាន គណនី ទំនាក់ទំនង ផ្ទេរប្រតិបត្តិការផ្សេងៗ (លេខ ៤៣០២)។

សក្ខីបត្រ÷

-អាណត្តិបើកប្រាក់ផ្តល់ឧបត្ថម្ភធនពីថវិការដ្ឋ (ច្បាប់ថតចម្លង)

-ប្រកាសឥណទានរបស់រតនាគារថ្នាក់កណ្តាល

-សលាកបត្រចុះលេខនា។

**ខ. កិច្ចបញ្ជិកាគណនេយ្យរបស់រតនាគាររាជធានី ខេត្ត÷**

ឥណពន្ធ គណនី ទំនាក់ទំនង ផ្ទេរប្រតិបត្តិការផ្សេងៗ (លេខ ៤៣០២)

ឥណទាន គណនី ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ជាប្រាក់រៀល (លេខ ៤៤០៥១)។

សក្ខីបត្រ÷

-អាណត្តិបើកប្រាក់ផ្តល់ឧបត្ថម្ភធនពីថវិការដ្ឋ (ច្បាប់ថតចម្លង)

-ប្រកាសឥណទានផ្ទេរឧបត្ថម្ភធនរបស់រតនាគារថ្នាក់កណ្តាល

-លិខិតជូនដំណឹងឥណទានរបស់រតនាគាររាជធានី ខេត្ត

-សលាកបត្រចុះលេខនា។

**គ. កិច្ចបញ្ជិការបស់គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល÷**

ឥណពន្ធ គណនី ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅរតនាគារ ជាប្រាក់រៀល (លេខ ១២០៥១)

ឥណទាន គណនី ឧបត្ថម្ភធនពីក្រសួង ស្ថាប័ន (លេខ ៧៥០១១)។

សក្ខីបត្រ÷

-អាណត្តិបើកប្រាក់ផ្តល់ឧបត្ថម្ភធនពីថវិការដ្ឋ (ច្បាប់ថតចម្លង)

-លិខិតជូនដំណឹងឥណទានរបស់រតនាគាររាជធានី ខេត្ត

-សលាកបត្រចុះលេខនា។

២.៣. ក្រោយបានទទួលទឹកប្រាក់ផ្តល់ឧបត្ថម្ភធនពីថវិកាជាតិ រតនាគាររាជធានី ខេត្ត ត្រូវកាត់សមតុល្យគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងជម្រះសមតុល្យគណនីបុរេប្រទានបន្ថែមសមតុល្យនៃគណនីប្រាក់បញ្ញើ។ ការកត់ត្រាដូចខាងក្រោម÷

**ក. កិច្ចបញ្ជិកាគណនេយ្យរបស់រតនាគាររាជធានី ខេត្ត÷**

ឥណពន្ធ គណនី ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ជាប្រាក់រៀល (លេខ ៤៤០៥១)

ឥណទាន គណនី បុរេប្រទានបន្ថែមសមតុល្យនៃគណនីប្រាក់បញ្ញើ (លេខ ១៥០៥៧)។

សក្ខីបត្រ÷

- លិខិតរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលស្នើទៅអគ្គនាយកដ្ឋានរតនាគារជាតិសុំផ្តល់ឧបត្ថម្ភធន (ច្បាប់ថតចម្លង)
- លិខិតជូនដំណឹងឥណពន្ធរបស់រតនាគាររាជធានី ខេត្ត
- សលាកបត្រចុះលេខនា។

**ខ. កិច្ចបញ្ជិការបស់គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល ÷**

ឥណពន្ធ គណនី បុរេប្រទានបានទទួល (លេខ ១១០៨)

ឥណទាន គណនី ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល នៅរតនាគារ ជាប្រាក់រៀល (លេខ ១២០៥១)។

សក្ខីបត្រ÷

- លិខិតរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលស្នើទៅអគ្គនាយកដ្ឋានរតនាគារជាតិសុំផ្តល់ឧបត្ថម្ភធន (ច្បាប់ថតចម្លង)
- លិខិតជូនដំណឹងឥណពន្ធរបស់រតនាគាររាជធានី ខេត្ត
- សលាកបត្រចុះលេខនា។

ទទួលបានសារាចរណែនាំនេះ សូម នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងនាយកគ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តសារាចរណែនាំនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ១៣ កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងអាណាព្យាបាលបច្ចេកទេស
- គ្រប់អង្គភាពពាក់ព័ន្ធ
- គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៣៧៧.ឧស.ភឧ.ប្រក.១១

ថ្ងៃ ព្រហស្បតិ៍ ៥កើត ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០១៨

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/ ០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្រកាសបង្កើតរោងចក្រផលិតបារី ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ក្រុមហ៊ុន ហ្វាយ ស្ទេត ថឺប៉ែកខូ ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ហ្វាយ ស្ទេត ថឺប៉ែកខូ ឯ.ក (FIVE STATES TOBACCO CO., LTD.) តំណាងដោយលោក យ៉ាន ណារ៉ុង បង្កើតរោងចក្រផលិតបារី ដែលមានទីតាំងស្ថិតនៅ ភូមិប្រហ៊ូត សង្កាត់រការក្រៅ ក្រុងដូនកែវ ខេត្តតាកែវ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
| --- | --- |
| បារី | ១២០០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ៖** "រោងចក្រផលិតបារី ហ្វាយ ស្មេត ចឺប៊ែកខូ ឯ.ក"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រង រោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានទាប់ហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តតាកែវ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

រដ្ឋលេខាធិការ

ហេង សុខគង់

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គនាយកដ្ឋានរាជកិច្ច និងតម្កល់ឯកសារជាតិ
- វិទ្យាស្ថានស្តង់ដារកម្ពុជា
- មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- សាលាខេត្តតាកែវ
- មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តតាកែវ
- រដ្ឋបាលក្រុងដូនកែវ
- រដ្ឋបាលសង្កាត់រកាក្រៅ

"ដើម្បីជូនជ្រាប"
- ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៣៧៤ ឧ.ស.ក.ស/ប្រ.ក-១១

ថ្ងៃព្រហស្បតិ៍ ៨កើត ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្រកាសបង្កើតរោងចក្រផលិតបារី ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ក្រុមហ៊ុន ខេមបូឌាន សៅអ៊ីស្ត អេស៊ា ថឹបែខូ ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ខេមបូឌាន សៅអ៊ីស្ត អេស៊ា ថឹបែខូ ឯ.ក (CAMBODIAN SOUTHEAST ASIA TOBACCO CO., LTD) តំណាងដោយ លោក ស៊ុន ប៊ុនហេង បង្កើតរោងចក្រផលិតបារី ដែលមានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៦A ភូមិកណ្តាល ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax: 855-23-428263

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| បារី | ១២០០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ៖** " រោងចក្រផលិតបារី ខេមបូឌាន សៅអ៊ីស្ត អេស៊ា ថឹប៊ែខូ ឯ.ក"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួង ឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រង រោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានទាន់ពេលវេលាអំពីករណីប្រែប្រួល ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាម មាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**ហេង សុខគង់**

**ចម្លងជូន៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងបរិស្ថាន
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -អគ្គនាយកដ្ឋានរាជកិច្ច និងតម្កល់ឯកសារជាតិ
- -វិទ្យាស្ថានស្តង់ដារកម្ពុជា
- -មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- -សាលាខេត្តកណ្តាល
- -មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកណ្តាល
- -រដ្ឋបាលស្រុកមុខកំពូល
- -រដ្ឋបាលឃុំព្រែកអញ្ចាញ
  "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០១៥៤ រ.ថ.អប្រក.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
## លេខ ០១៥៤ រ.ថ.អប្រក.លអ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៨

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៧/១២១៣ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤០១ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្ទេរនិងសមាហរណកម្មអាជ្ញាធរប្រេងកាតជាតិកម្ពុជា ទៅក្រោមក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសរួមលេខ ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈនិងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈនិងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង

និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៨ របស់លោក ផន ភារិទ្ធ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌក្នុងការផ្តល់ លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ យីហោ ស្ថានីយប្រេងឥន្ធនៈ រិទ្ធី ស្ថិតនៅ ភូមិអង្គ្រង ឃុំកន្ទ្រាំង ស្រុកប្រាសាទបាគង ខេត្តសៀមរាប របស់ **លោក ផន ភារិទ្ធ** (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញ លិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពលដោយត្រូវបំពេញបន្ថែមនូវឯកសារ ដូចខាងក្រោម ក្នុងរយៈពេល ១ (មួយ) ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

១. លិខិតបញ្ជាក់អនុញ្ញាតទីតាំងពីអាជ្ញាធរដែនដីរាជធានី-ខេត្ត

២. លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាម សារាចរខាងលើឲ្យចប់ជាស្ថាពរមុនថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ នូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. ត្រូវមានកបំពង់ទទួលប្រេងឥន្ធនៈ ពីរថយន្តផ្ទេរប្រេងឥន្ធនៈ

២. មិនអនុញ្ញាតឲ្យមានលំនៅដ្ឋាន ក្នុងបរិវេណស្ថានីយប្រេងឥន្ធនៈ

៣. ត្រូវមានគន្លឹះអាសន្នរួម និងគន្លឹះអាសន្នតាមទូចាក់ប្រេងឥន្ធនៈនីមួយៗ

៤. ត្រូវមានស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឲ្យបានគ្រប់គ្រាន់ និងបំពាក់ផ្ទាំងព័ត៌មានស្តីពីនីតិវិធី នៃការផ្ទេរប្រេងឥន្ធនៈ

៥. ពោងប្រេងឥន្ធនៈទាំងអស់ ត្រូវកប់ក្នុងដី
៦. ពោងប្រេងឥន្ធនៈមួយ ដាក់ប្រេងឥន្ធនៈបានមួយប្រភេទប៉ុណ្ណោះ
៧. ទីតាំងទូចាក់ប្រេងឥន្ធនៈ ត្រូវស្ថិតនៅចម្ងាយ ៦ម៉ែត្រ ពីអគារការិយាល័យ
៨. ទុយោចាក់ប្រេងឥន្ធនៈ ត្រូវមានប្រវែងអតិបរមា ៦ម៉ែត្រ
៩. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមក ក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាព នៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់មកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែ និងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឲ្យការគ្រប់គ្រងស្ថានីយឱ្យមានប្រសិទ្ធិភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ មកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែ និងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិចមុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ ០២៥ [illegible] ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១៨ របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះ ផ្អាកដំណើរការជាប់ៗ គ្នាក្នុងរយៈពេល១២ (ដប់ពីរ) ខែឬប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះ លិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០១៥៤.រ៉ែ.អ.ប.រ.ល.ណអ.....ចុះថ្ងៃទី...០៣..ខែ...ធ្នូ.......ឆ្នាំ២០១៨ នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាតអគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តសៀមរាប និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ....១១រោច.ខែ..កត្តិក...ឆ្នាំច..សំរឹទ្ធិស័ក.ព.ស. ២៥៦២

ធ្វើនៅភ្នំពេញ ថ្ងៃទី...០៣...ខែ...ធ្នូ......ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ_សែម**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចឯកឧត្តមលោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តសៀមរាប
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខៈ ០១៤៤ ម៉.ធ្ម.ប្រក.ប្រក

ប្រកាស
ស្តីពី
លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
លេខ ០១៤៤ ម៉.ធ្ម.ប្រក.ឈ្មួ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៨

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៧/១២១៣ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤០១ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្ទេរនិងសមាហរណកម្មអាជ្ញាធរប្រេងកាតជាតិកម្ពុជា ទៅក្រោមក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៨ របស់លោក សាម ហេង
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌក្នុងការផ្តល់ លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេង និងឧស្ម័នឥន្ធនៈ មានស្លាកយីហោស្ថានីយប្រេងឥន្ធនៈ ម៉ៅ សុខហ៊ាង ស្ថិតនៅផ្លូវជាតិលេខ៤១ ភូមិចំបក់ក្អែរ ឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺរបស់លោក សាម ហេង (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញ លិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពលដោយត្រូវបំពេញបន្ថែមនូវឯកសារ ដូចខាងក្រោម ក្នុងរយៈពេល ១ (មួយ) ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

១. លិខិតអនុញ្ញតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាម សារាចរខាងលើឲ្យចប់ជាស្ថាពរមុនថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ នូវចំណុចបច្ចេកទេសដូចខាងក្រោម៖

១. ត្រូវរៀបចំគំនូសសញ្ញាសម្រាប់ចំណតរថយន្តស៊ីទែនផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ

២. ត្រូវរៀបចំកបំពង់ទទួលប្រេងឥន្ធនៈ ដាក់ក្នុងឃ្លុបការពារ និងមាននីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ

៣. ត្រូវរុះរើពោងប្រេងឥន្ធនៈដែលបានដាក់នៅលើដីចេញ

៤. ពោងឧស្ម័នឥន្ធនៈត្រូវមានចំណុះមិនលើសពី១០តោន

៥. ទូចាក់ឧស្ម័នឥន្ធនៈត្រូវមានចម្ងាយ៧,៥០ម៉ែត្រពីអគារលក់ទំនិញ និងរបងព្រំដីស្ថានីយ

៦. ត្រូវរៀបចំចង្អូរប្រមូលទឹកចោល អាងញែកសំណល់រឹង ប្រេង និងទឹក។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមក ក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាព នៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឲ្យការគ្រប់គ្រងស្ថានីយឱ្យមានប្រសិទ្ធិភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ មកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែ និងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិចមុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០១៥៥ ស.ជ.ឧ.ប.ក.ឯអ..........ចុះថ្ងៃទី..០៣....ខែ...ធ្នូ......ឆ្នាំ២០១៨ របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះ ផ្អាកដំណើរការជាប់ៗ គ្នាក្នុងរយៈពេល១២ (ដប់ពីរ) ខែឬប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះ លិខិតអនុញ្ញាតដំណើរការស្ថានីយលេខ...០១[illegible]...ចុះថ្ងៃទី...០៣...ខែ...ធ្នូ.......ឆ្នាំ២០១៨ នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តកំពង់ស្ពឺ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ...១១រោច...ខែ...ធ្នូ.......ឆ្នាំច...សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅភ្នំពេញ ថ្ងៃទី...០៣...ខែ...ធ្នូ.......ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេចឯកឧត្តមលោកជំទាវឧបនាយករដ្ឋមន្ត្រី
- -សាលាខេត្តកំពង់ស្ពឺ
- -ដូចប្រការ១៣
- -រាជកិច្ច
- -ឯកសារកាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខៈ ០១៦២ រ៉ថ.អប្រក.ប្រក

## ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
## លេខ ០១៦២ រ៉ថ.អប្រក.ប្រក ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៨

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ខែកញ្ញាឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ខែមិថុនាឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៧/១២១៣ចុះថ្ងៃទី០៩ខែធ្នូឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤០១ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្ទេរនិងសមាហរណកម្មអាជ្ញាធរប្រេងកាតជាតិកម្ពុជា ទៅក្រោមក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ៥៧៦ អនក្រ.បកចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ខែវិច្ឆិកាឆ្នាំ២០១៥របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈនិងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រកចុះថ្ងៃទី០៣ខែកុម្ភៈឆ្នាំ២០១៧របស់ក្រសួងរ៉ែនិងថាមពលនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ខែវិច្ឆិកាឆ្នាំ២០១៥ស្តីពីការផ្តល់សេវាសាធារណៈនិងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយចម្រុះប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរចចុះថ្ងៃទី១៦ខែឧសភាឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៨ របស់លោក Asif IQBAL
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈមានស្លាកយីហោស្ថានីយប្រេងឥន្ធនៈ តូតាល់ បាត់ដំបង ॥ ស្ថិតនៅភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង របស់ក្រុមហ៊ុន តូតាល់កម្ពុជា (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រកចុះថ្ងៃទី១៦ខែឧសភាឆ្នាំ២០១៨ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែនិងថាមពលដោយត្រូវបំពេញបន្ថែមនូវឯកសារ ដូចខាងក្រោម ក្នុងរយៈពេល ១ (មួយ) ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

១. លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរចចុះថ្ងៃទី១៦ខែឧសភាឆ្នាំ២០១៨ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឲ្យចប់ជាស្ថាពរមុនថ្ងៃទី២៥ខែវិច្ឆិកា ឆ្នាំ២០១៩។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែនិងថាមពលក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែនិងថាមពលមុនប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួនប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យបរិមាណប្រេងឥន្ធនៈដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១នៃត្រីមាសបន្ទាប់និងប្រចាំឆ្នាំនៅសប្តាហ៍ទី១នៃឆ្នាំបន្ទាប់មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឲ្យការគ្រប់គ្រងស្ថានីយឱ្យមានប្រសិទ្ធិភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាតឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិចមុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាពនៃលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០១៦៧.រ៉ែ.អប្រក.លអ..........ចុះថ្ងៃទី....០៣..ខែ..ធ្នូ........ឆ្នាំ២០១៨របស់ក្រសួងរ៉ែនិងថាមពលនិងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះនិងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ) ខែឬប្រព្រឹត្តល្មើសច្បាប់ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០១៦៧.រ៉ែ.អប្រក.លអ ចុះថ្ងៃទី.០៣..ខែ...ធ្នូ.......ឆ្នាំ២០១៨ នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។



ប្រការ១៣.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការប្រធានមន្ទីររ៉ែនិងថាមពលខេត្តបាត់ដំបងនិងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃច័ន្ទ...១១រោច..ខែ..កត្តិក...ឆ្នាំច..សំរឹទ្ធិស័ក..ព.ស. ២៥៦២
ធ្វើនៅភ្នំពេញ ថ្ងៃទី..០៣.....ខែ..ធ្នូ......ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្ដេចឯកឧត្តមលោកជំទាវឧបនាយករដ្ឋមន្ត្រី
-សាលាខេត្តបាត់ដំបង
-ដូចប្រការ១៣
-រាជកិច្ច
-ឯកសារកាលប្បវត្តិ

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្ដីការគណៈរដ្ឋមន្ត្រី